# សិទ្ធិជនអន្តោប្រវេសន៍

## តើអ្វីខ្លះដែលគ្រួសារជនអន្តោប្រវេសន៍អាចធ្វើបានឥឡូវនេះ?

### ➲ ពិគ្រោះជាមួយអ្នកផ្តល់សេវាជនអន្តោប្រវេសន៍ អំពីជម្រើសអន្តោប្រវេសន៍របស់អ្នក

រកជំនួយផ្នែកច្បាប់អំពីអន្តោប្រវេសន៍
នៅលើបញ្ជីរាយឈ្មោះអង្គការជំនួយតស៊ូមតិដើម្បីជនអន្តោប្រវេសន៍ថ្នាក់ជាតិ ដោយឥតគិតថ្លៃ ឬធូរថ្លៃ តាមគេហទំព័រនេះ៖ https://www.immigrationlawhelp.org

- បើអ្នកមានប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ (Green Card) សូមរកមើលព័ត៌មានសម្រាប់ចូលសញ្ជាតិអាមេរិក។
- បើអ្នកចូលមកអាមេរិកតាមទិដ្ឋាការណាមួយ សូមរកមើលវិធីសុំប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ (Green Card)។
- បើអ្នកពុំមានឯកសារបញ្ជាក់ស្ថានភាពអន្តោប្រវេសន៍ សូមរកមើលក្រែងអ្នកអាចដាក់ពាក្យសុំទិដ្ឋាការ ឬលិខិតអនុញ្ញាតធ្វើការ។
- បើអ្នកមានដីកាចាប់ខ្លួន ឬផ្តន្ទាទោស សូមរកមើលថាបញ្ហានេះ ប៉ះពាល់ដល់ករណីអ្នកយ៉ាងណា ឬតើមានវិធីណាដើម្បីលុបវាចេញពីប្រវត្តិរូបរបស់អ្នកបានដែរទេ។

### ➲ រៀបចំផែនការត្រៀមខ្លួនសម្រាប់ថែទាំកូនៗ និងគ្រួសារ

**(https://www.ilrc.org/family-preparedness-plan)**

- សូមរៀបចំទុកដាក់ព័ត៌មានផ្សេងៗ និងព័ត៌មានទាក់ទងក្នុងបន្ទាន់ ឲ្យបានទាន់សភាពការណ៍ សម្រាប់កូននៅសាលារៀន និងត្រូវចាត់ចែងថានរណាទៅទឹកកូនចេញពីសាលា។
- បង្កើតតារាងមួយមានលេខទូរស័ព្ទទាក់ទងគ្រាមានអាសន្ន និងដាក់ឯកសារសំខាន់ៗមួយដុំ ដើម្បីអ្នក និងគ្រួសារអ្នក អាចរកអ្នកជួយបន្ទាន់។
- បំពេញលិខិតផ្ទេរសិទ្ធិឲ្យគេមើលថែកូនជំនួស ដើម្បីឲ្យមនុស្សពេញវ័យណាម្នាក់ អាចមើលថែកូនៗរបស់អ្នក ជាបណ្តោះអាសន្ន (រដ្ឋកាលីហ្វ័រញ៉ាមានលិខិតនេះ)។
- ចុះកំណើតរបស់កូនអ្នកជាមួយរដ្ឋាភិបាលនៃប្រទេសអ្នក (ឧទាហរណ៍ ជាមួយកុងស៊ុលនៃប្រទេសអ្នក) បើកូនអ្នកកើតនៅសហរដ្ឋអាមេរិក។

### ➲ រកមើលថាតើឯកសារណាខ្លះ អ្នកគួរ និងមិនគួរយកតាមខ្លួន

- បើអ្នកមានលិខិតអនុញ្ញាតធ្វើការ ឬប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ (Green Card) សូមយកវាតាមខ្លួនគ្រប់ពេល។ បើអ្នកពុំមានឯកសារនេះ ជាការល្អអ្នកត្រូវយកតាមខ្លួនប័ណ្ណសំខាន់ខ្លួនរបស់សាលាក្រុង អត្តសញ្ញាណប័ណ្ណចេញដោយរដ្ឋ ឬប័ណ្ណបើកបរ បើឯកសារនេះចេញដោយសហរដ្ឋអាមេរិក និងមិនមានរៀបរាប់អ្វីទាំងអស់អំពីស្ថានភាពអន្តោប្រវេសន៍របស់អ្នក ឬប្រទេសកំណើតរបស់អ្នក។ សួរអ្នកតស៊ូមតិជួយជនអន្តោប្រវេសន៍នៅមូលដ្ឋាន អំពីថាតើឯកសារណាមួយ ដែលមានសុវត្ថិភាព ក្នុងការយកតាមខ្លួន នៅក្នុងតំបន់របស់អ្នក។
- ហាមយកតាមខ្លួនរាល់ឯកសារណា ដែលប្រាប់អំពីប្រទេសកំណើតរបស់អ្នក។
- ហាមយកតាមខ្លួនឯកសារក្លែងក្លែងអំពីអត្តសញ្ញាណ ឬឯកសារអន្តោប្រវេសន៍ក្លែងក្លាយ។
- គ្រប់ពេលទាំងអស់ គឺត្រូវយកប័ណ្ណក្រហមតាមខ្លួន (https://www.ilrc.org/red-cards) ដើម្បីអនុវត្តសិទ្ធិនៅស្ងៀម មិននិយាយស្តី ក្នុងករណីប៉ូលិសអន្តោប្រវេសន៍ (ICE) ឃាត់ដើម្បីសួរនាំ។

# សិទ្ធិរបស់អ្នករាល់គ្នា ក្នុងអំឡុងពេលប៉ូលិសអន្តោប្រវេសន៍ (ICE) ចុះចាប់ខ្លួន

អ្នករាល់គ្នា — ទាំងអ្នកមានឯកសារ និងគ្មានឯកសារ សុទ្ធតែមានសិទ្ធិនៅក្នុងប្រទេសនេះ។

## ➲ ធ្វើយ៉ាងណាអ្នក និងអ្នកដទៃទៀត ត្រូវដឹងថាត្រូវធ្វើអ្វីខ្លះ បើមានប៉ូលិសអន្តោប្រវេសន៍ (ICE) មកឃាត់សួរនាំ។

ប្រាប់គ្រួសាររបស់អ្នក (សូម្បីតែកូនៗ) អ្នកនៅផ្ទះជាមួយគ្នា អ្នកជិតខាង និងសហការី មិនថាពួកគាត់មានស្ថានភាពអន្តោប្រវេសន៍បែបណានោះឡើយ ប្រាប់ពួកគាត់អំពីសិទ្ធិនៅស្ងៀម មិននិយាយស្តី និងសិទ្ធិទាំងអស់នេះ បើប៉ូលិសអន្តោប្រវេសន៍ (ICE) ទៅដល់ផ្ទះអ្នក ផ្ទះអ្នកជិតខាង ឬកន្លែងធ្វើការ។

## ➲ អ្នកមានសិទ្ធិនៅស្ងៀមមិននិយាយស្តី។

អ្នកអាចប្រកែកមិននិយាយទៅកាន់ប៉ូលិសអន្តោប្រវេសន៍ (ICE)។ សូមកុំឆ្លើយអ្វីទាំងអស់ ជាពិសេសអំពីកន្លែងកំណើតរបស់អ្នក ស្ថានភាពអន្តោប្រវេសន៍របស់អ្នក ឬថាតើអ្នកចូលមកអាមេរិកដោយរបៀបណា។ សូមនិយាយថា អ្នកសូមរក្សាសិទ្ធិនៅស្ងៀម រហូតដល់បានជួបនិយាយជាមួយមេធាវីសិន។

## ➲ អ្នកមានសិទ្ធិទាមទារសុំមើលដីកា មុនអនុញ្ញាតឲ្យនរណាម្នាក់ចូលក្នុងផ្ទះអ្នក។

ហាមបើកទ្វារឲ្យអាជ្ញាធរចូលផ្ទះ ទាំងគ្មានដីការ។ អ្នកមិនចាំបាច់បើកទ្វារនោះទេ លើកលែងតែប៉ូលិសអន្តោប្រវេសន៍ (ICE) បង្ហាញដីកា ដែលចុះហត្ថលេខាដោយចៅក្រម និងមានឈ្មោះរបស់អ្នកត្រឹមត្រូវ និងអាសយដ្ឋានអ្នកនៅលើដីកានោះ។ បើប៉ូលិសថាពួកគេមានដីកានេះ សូមកុំបើកទ្វារឲ្យពួកគេ បង្ហាញវា។ សូមប្រាប់ពួកគេឲ្យហុចវាតាមក្រោមទ្វារ ឬតាមមាត់បង្អួច។

## ➲ អ្នកមានសិទ្ធិនិយាយជាមួយមេធាវី និងសិទ្ធិទូរស័ព្ទ។

## ➲ អ្នកមានសិទ្ធិប្រកែកមិនព្រមចុះហត្ថលេខាលើអ្វីមួយ មុនអ្នកបាននិយាយជាមួយមេធាវីសិន។

ហាមចុះហត្ថលេខាលើអ្វីក៏ដោយ។ នោះអាចធ្វើឲ្យអ្នកបាត់បង់សិទ្ធិ ក្នុងការនិយាយជាមួយមេធាវី ឬមានសវនាការនៅចំពោះចៅក្រមអន្តោប្រវេសន៍។ នេះអាចឈានទៅការចាប់បញ្ជូនខ្លួនអ្នកភ្លាមៗ ដោយពុំមានសវនាការ។

## ➲ អ្នកមានសិទ្ធិប្រកែកមិនព្រមបង្ហាញឯកសារណាមួយ នៅមុនបាននិយាយជាមួយមេធាវីសិន។

| សូមរក្សាការស្ងប់ស្ងៀម និងកុំព្យាយាមរត់គេច។ |
| --- |

## តើសម្ព័ន្ធមិត្តអាចជួយអ្វីបានខ្លះ ក្នុងពេលគេចុះចាប់

**➲ បើអ្នកអាចធ្វើបានដោយសុវត្ថិភាព សូមថតរូប ថតវីដេអូ កត់ត្រា និងរាយការណ៍អំពីការចុះចាប់នោះ។**

- យកឈ្មោះ និងទូរស័ព្ទសាក្សីណាម្នាក់។
- ផ្សព្វផ្សាយព័ត៌មានចុះចាប់នេះបន្តទៅអ្នកធ្វើការជាមួយ។ បើមានសហជីព នៅកន្លែងធ្វើការ ទាក់ទងមន្ត្រីសហជីព។
- បើប៉ូលិសអន្តោប្រវេសន៍ (ICE) សម្រុកចូលដោយគ្មានដីកាត្រឹមត្រូវ អ្នកត្រូវសុំឈ្មោះពួកគាត់ និង/ឬ កត់លេខសម្គាល់ខ្លួនរបស់ពួកគាត់។

**➲ ដើម្បីរាយការណ៍អំពីការចុះចាប់ សូមទាក់ទងលេខហត់ឡាញរបស់អង្គការ United We Dream នេះ 1-844-363-1423 ឬផ្ញើសារទៅលេខ 877877។**
រាយការណ៍អំពីសកម្មភាពចុះចាប់ណាមួយ ឬការបំពាន/ការធ្វើបាបណាមួយពីប៉ូលិសអន្តោប្រវេសន៍ (ICE) ឬប៉ូលិសទូទៅ ឬប៉ូលិសល្បាតព្រំដែន។